ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

easy speaking MONSOON Paper Tiger

# កិច្ចព្រមព្រៀងការងារ

រវាង

**បុគ្គលិក និង និយោជក លើកទី ៤**

**ចំនួន ៨២ នាក់ ដែលមានស្រី ចំនួន ៤៦ នាក់**

ដោយសារស្ថានភាពប្រទេសកម្ពុជា ក៏ដូចជាពិភពលោក កំពុងប្រឈមវិបត្តិរងគ្រោះដោយជម្ងឺប៉ះពាល់ប្រព័ន្ធផ្លូវដង្ហើម (Covid19) ហើយបានធ្វើអោយបណ្តាប្រទេសនានាជុំវិញពិភពលោក បានបិទជើងហោះហើរការធ្វើដំណើររបស់ភ្ញៀវទេសចរ ក៏ដូចជាប្រជាជនរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនិងជម្ងឺ Covid19 បានធ្វើអោយប្រទេសកម្ពុជា យើងទទួលផលប៉ះពាល់ស្ទើរទាំងស្រុងដែលមិនមានភ្ញៀវទេសចរ ធ្វើដំណើរចូលមកទស្សនា ឬលេងកំសាន្តនោះទេ ។

ដោយស្ថានភាពនេះបានបង្ករអោយក្រុមហ៊ុន **ម៉ុនសូន អេស៊ាន ប៊ីស្ត្រូ** ( MONSOON ASIAN BISTRO ) យើងមិនអាចដំណើរការអាជីវកម្មរបស់ខ្លួនបាន ដូច្នេះសម្រេចធ្វើកិច្ចព្រមព្រៀងដូចខាងក្រោម៖

**ប្រការ ១៖** ធ្វើការបិទក្រុមហ៊ុន **ម៉ុនសូន អេស៊ាន ប៊ីស្ត្រូ** មួយរយៈពេលចំនួន **៦០** ថ្ងៃដោយគិត ចាប់ពី **ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០២១** ។

**ប្រការ២៖** បុគ្គលិកទាំងអស់ដែលបម្រើការងារអោយក្រុមហ៊ុន **ម៉ុនសូន អេស៊ាន ប៊ីស្ត្រូ** ត្រូវបានអនុញ្ញាតឲ្យធ្វើការសម្រាកក្នុងរយៈពេលនៃការបិទខាងលើ ដោយមិនទទួលបានប្រាក់សំណង ឬ ឧបត្ថម្ភពីក្រុមហ៊ុននោះឡើយ លើកលែងតែមានការឧបត្ថម្ភពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣៖** នៅពេលក្រុមហ៊ុនបើកដំណើរការអាជីវកម្មរបស់ខ្លួនឡើងវិញ បុគ្គលិកទាំងអស់របស់ក្រុមហ៊ុនត្រូវបានអនុញ្ញាតអោយចូលបម្រើការងារតាមតួនាទី និង មុខតំណែងរបស់ខ្លួនជាធម្មតា ហើយប្រាក់ខែ និងផលប្រយោជន៍ផ្សេងៗរបស់បុគ្គលិកក៏ទទួលបានដោយពុំមានការកាត់ចោលឡើយ ។

**ប្រការ៤៖** បុគ្គលិក ឬ តំណាងអោយបុគ្គលិកបានអាននិងយល់ព្រមលើកិច្ចព្រមព្រៀងនេះដោយការផ្តិតមេដៃដើម្បីធ្វើជាសក្ខីកម្ម ឬ ភស្តុតាងនៃឯកសារគតិយុត្ត ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ ។

**ប្រការ ៥៖** រាល់សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយពីខ្លឹមសារខាងលើត្រូវទុកជានិរាសក៍ ។

**សៀមរាបថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០២០**

| **តំណាងបុគ្គលិកទី១** | **តំណាងបុគ្គលិកទី២** | **តំណាងអគ្គនាយកក្រុមហ៊ុន** |
|---|---|---|
| ឈ្មោះ អ៊ុំ ន្ឌួត | ឈ្មោះ ដី ភិរមសិទ្ធិត្ថា | MONSOON Asian Fusion & Bistro Siem Reap, Cambodia |
| | | **ចៅ សុវណ្ណា** |